ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លាដំបូងរាជធានីភ្នំពេញ

រឿងព្រហ្មទណ្ឌលេខ ៣៣១០
ទី១៣ ខែកក្កដា ឆ្នាំ២០១៦
រឿងជំនុំជម្រះលេខ ៨១០៥
ទី០៥ ខែធ្នូ ឆ្នាំ២០១៦
ក្រមលេខ: ១១៨ "ហ"ក្រ៥
ទី៣១ ខែមីនា ឆ្នាំ២០១៧

## សាលក្រមព្រហ្មទណ្ឌ

**តាងនាមប្រជារាស្ត្រខ្មែរ**

សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ ដោយមានសមាសភាពចូលរួមដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើ សំណុំរឿងព្រហ្មទណ្ឌលេខ ៣៣១០ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ដែលមានជនជាប់ចោទ:

១-ឈ្មោះ [redacted] ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរកម្មកររោងចក្រ ទីកន្លែងកំណើតនៅភូមិត្រពាំងគល់ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] -ស្លាប់- ម្តាយឈ្មោះ [redacted] -រស់- ប្តីឈ្មោះ [redacted] -រស់- មានកូន០១នាក់ ជានីតិជន ទោសពីមុនគ្មាន ។

-អំពីការឃុំខ្លួន: ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ៤២៩៣ "ជ"ដយជ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ ។

២-ឈ្មោះ [redacted] ភេទស្រី អាយុ៤៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិអង្គស្នួលទី១ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នភូមិអង្គស្នួលទី១ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] -ស្លាប់- ម្តាយឈ្មោះ [redacted] -ស្លាប់- ប្តីឈ្មោះ [redacted] -រស់- មានកូន០១នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (គេចខ្លួន)

ជាប់ចោទពីបទ ក្លែងបន្លំឯកសារសារធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៦២៩ និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ។

-លោក [redacted] ជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted]

-លោក [redacted] ជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted]



Scanned by CamScanner

## អង្គហេតុនៃរឿងដើមមានដូចតទៅ:

កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ឈ្មោះ[redacted]និងគូកន (ឈ្មោះ [redacted]បានក្លែងបន្លំឯកសារដោយបានក្លែងលិខិតផ្ទេរសិទ្ធកាន់កាប់ដី/ផ្ទះលេខ ១១៣ ប.ជ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ចុះហត្ថលេខាដោយលោក[redacted]ជាមេឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល ហើយឈ្មោះ[redacted]បានបន្លំធ្វើជាឈ្មោះ[redacted]រួចនាំគ្នាយកឯកសារក្លែងបន្លំ ទាំងនេះទៅដាក់តម្កល់ខ្ចីប្រាក់ពីឈ្មោះ[redacted]បានប្រាក់រួច ក្រោយមកក៏នាំគ្នាគេចខ្លួនបាត់តែម្តង ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ៣១៤៧ អ.យ.ឃ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ: ៤០៦២ "ជ" ដជ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា: កាលពីអំឡុងឆ្នាំ២០១៦ ឈ្មោះ[redacted]និង ឈ្មោះ[redacted]ជាក្មួយរបស់ឈ្មោះ[redacted] បានទំនាក់ទំនងជាមួយឈ្មោះ[redacted] ដើម្បីខ្ចីប្រាក់ចំនួន ១០.០០០ (មួយម៉ឺន)ដុល្លារអាមេរិក ហើយឈ្មោះ[redacted]និងឈ្មោះ[redacted]បានឲ្យខ្លួនទៅយកប្រាក់ពីឈ្មោះ[redacted]ដោយពេលទៅនោះមានឈ្មោះ[redacted] និងឈ្មោះ[redacted]ទៅជាមួយខ្លួនដែរ និងយកលិខិតផ្ទេរសិទ្ធកាន់កាប់ដី/ផ្ទះលេខ ១១៣ ប.ជ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ (ថតចម្លង) ដើម្បីដាក់ជាការបញ្ចាំ ។ នៅពេលដែលយកប្រាក់បានហើយឈ្មោះ[redacted]បានឲ្យប្រាក់ខ្លួនចំនួន ២០០ (ពីរយ)ដុល្លាអាមេរិក ជាថ្លៃទឹកតែ ។ ខ្លួនពុំដែលស្គាល់ឈ្មោះ[redacted]នោះទេ ពេលទៅយកប្រាក់នោះបានហើយ ខ្លួនយកឯកសារថតចម្លងយកទៅឲ្យឈ្មោះ[redacted]ហើយ យកប្រាក់នោះទៅលោះប្លង់ធនាគារ ទើបខាងធនាគារប្រគល់ប្លង់ដើមឲ្យវិញ ។ ឈ្មោះ[redacted]បានយករូបថតខ្លួន ០១ (មួយ)សន្លឹក និងអត្តសញ្ញាណប័ណ្ណ ០១ (មួយ)សន្លឹក ហើយឲ្យខ្លួនបានប្រាប់ឈ្មោះ[redacted] ថាខ្លួនឈ្មោះ[redacted] ដោយបានឲ្យអត្តសញ្ញាណប័ណ្ណឈ្មោះ[redacted]ទៅឈ្មោះ[redacted]មើល ប៉ុន្តែរូបថតក្នុងអត្តសញ្ញាណប័ណ្ណនោះជារូបរបស់ខ្លួន ។ ចំពោះឈ្មោះ[redacted] ពុំដឹងថាខ្លួនឈ្មោះ[redacted] នោះទេ គឺដឹងថាខ្លួនឈ្មោះ[redacted]។ ចំណែកលិខិតផ្ទេរសិទ្ធកាន់កាប់ដី/ផ្ទះលេខ ១១៣ ប.ជ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ នោះខ្លួនពុំបានដឹងថាមានបញ្ហាអ្វីនោះទេ ទើបតែដឹងថាមានបញ្ហាពេលយកប្រាក់រួចហើយ ។ ខ្លួនស្គាល់និងរាប់អានជាមួយឈ្មោះ[redacted]។ ពេលខ្លួនទៅខ្ចីប្រាក់នោះគឺបានកាន់លិខិតផ្ទេរសិទ្ធកាន់កាប់ដី/ផ្ទះលេខ ១១៣ ប.ជ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ (ថតចម្លង)មួយច្បាប់ ពេលចុះកិច្ចសន្យានោះគឺឈ្មោះ[redacted] បានឲ្យខ្លួនផ្តិតមេដៃជំនួសឈ្មោះ[redacted] ខ្លួនទទួលស្គាល់ថារូបក្នុងអត្តសញ្ញាណប័ណ្ណថតចម្លងរបស់ឈ្មោះ[redacted]នោះគឺជារូបខ្លួនពិតមែន ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]បានឆ្លើយថា: ខ្លួនពុំដែលស្គាល់ឈ្មោះ[redacted] នោះទេ ។ នៅពេលមកខ្ចីប្រាក់នោះគឺឈ្មោះ[redacted] ជាអ្នកនាំឈ្មោះ[redacted]ងឈ្មោះ[redacted]មកខ្ចីប្រាក់ដើម្បីទៅលោះប្លង់នៅធនាគារ ។ នៅពេលខ្ចីប្រាក់ឈ្មោះ[redacted]បានប្រាប់ខ្លួនថាគាត់ឈ្មោះ [redacted] ។ ពេលមកខ្ចីប្រាក់ខ្លួន គឺឈ្មោះ[redacted] បានមកទំនាក់ទំនងខ្លួនថាខ្ចីប្រាក់ដើម្បីទៅលោះប្លង់នៅធនាគារ ខ្លួនក៏បានទៅធនាគារជាមួយឈ្មោះ[redacted]ឈ្មោះ[redacted]ដើម្បីទៅលោះប្លង់ដែរ តែខ្លួនមិនបានចូលទេដោយឈ្មោះ[redacted]ប្រាប់ថាឲ្យនៅចាំខាងក្រៅ ហើយពេលនោះខ្លួនរវល់



Scanned by CamScanner

មើលកូននៅខាងក្រៅក៏មិនបានចូលជាមួយពួកគេ លុះពេលនោះប្លង់បានហើយ ទើបឈ្មោះ [redacted] បានធ្វើកិច្ចសន្យាខ្ចីប្រាក់ជាមួយខ្លួន និងបានដាក់បញ្ចាំប្លង់នោះឲ្យខ្លួន ។ ខ្លួនបានប្រគល់ប្រាក់ឲ្យឈ្មោះ [redacted] នៅមុខធនាគារ ចំនួន ១០.០០០ (មួយម៉ឺន)ដុល្លាអាមេរិក និងយកការប្រាក់ចំនួន ៧០០ (ប្រាំពីររយ)ដុល្លាអាមេរិក ហើយឈ្មោះ [redacted] បានប្រាប់ខ្លួនថាខ្ចីតែពីបីថ្ងៃទេ ។ រយៈពេល ៥ ទៅ ៦ ខែ គឺមានការផ្ញើលុយតាមវីងមកម្តង ៥០០ (ប្រាំរយ)ដុល្លាអាមេរិក ដោយឈ្មោះ [redacted] ជាអ្នកវេលុយឲ្យខ្លួន ។ ក្រោយមកក៏បាត់ដំណឹងយូរពេក ខ្លួនក៏បានទៅសួរមេឃុំ ទើបដឹងថាលិខិតផ្ទេរសិទ្ធកាន់កាប់ដី/ផ្ទះលេខ ១១៣ ប.ជ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលឈ្មោះ [redacted] នដាក់បញ្ចាំខ្លួននោះគឺជាឯកសារក្លែងក្លាយ ។ ខ្លួនបានទទួលការសងប្រាក់ចំនួន ២០០០ (ពីពាន់)ដុល្លាអាមេរិករួចហើយ តែជាការប្រាក់ទេ ។ ក្នុងរឿងនេះខ្លួនសូមទាមទារប្រាក់ជំពាក់ចំនួន ១០.០០០ (មួយម៉ឺន)ដុល្លាអាមេរិក និងសំណងជម្ងឺចិត្តចំនួន ៥០០០ (ប្រាំពាន់)ដុល្លារអាមេរិក ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានៈ តាមចម្លើយរបស់ជនជាប់ចោទឈ្មោ[redacted]ថាបានប្រគល់រូបថតឲ្យឈ្មោះ [redacted] ដើម្បីយកទៅបិទបន្លំជាឈ្មោះ [redacted] ក្នុងអត្តសញ្ញាណប័ណ្ណ ហើយជនជាប់ចោទឈ្មោះ [redacted] បានយកអត្តសញ្ញាណប័ណ្ណនេះមកបន្លំធ្វើជាឈ្មោះ [redacted] រួចខ្ចីប្រាក់ពីជនរងគ្រោះ និងបានដាក់បញ្ចាំលិខិតផ្ទេរសិទ្ធកាន់កាប់ដី/ផ្ទះលេខ ១១៣ ប.ជ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលជាឯកសារក្លែង ឲ្យឈ្មោះ [redacted] ឃើញថាមានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទ ដូច្នេះសុំតម្កល់ការចោទប្រកាន់ និងសុំឲ្យចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-លោក [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោ[redacted]បានធ្វើសេចក្តីសន្និដ្ឋានថាៈ ប្រាក់ដែលខ្ចីនោះឈ្មោះ [redacted] បានសងប្រាក់ទៅដើមបណ្តឹងរដ្ឋប្បវេណីអស់ប្រហែល ៦០០០ (ប្រាំមួយពាន់)ដុល្លាអាមេរិក ទៅ ៧០០០ (ប្រាំពីរពាន់)ដុល្លាអាមេរិក ហើយតាមរយៈវីង ។ ហើយកូនក្តីខ្លួនសុខចិត្តសងប្រាក់ទៅដើមបណ្តឹងរដ្ឋប្បវេណីឲ្យគ្រប់ចំនួន ។ ខ្លួនសំណូមពរសុំឲ្យតុលាការកែប្រែបទចោទប្រកាន់លើកូនក្តីខ្លួន ពីបទ ក្លែងបន្លំឯកសារសារធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង ទៅជាបទ[redacted]ញ ។

-លោក [redacted] ជាមេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោ[redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថាៈ រឿងនេះមានភាពស្មុគស្មាញនៅឡើយ ដោយការរកស៊ីផ្អែកលើការទុកចិត្តគ្នា ហើយកូនក្តីខ្លួនមិនមែនជាអ្នកផ្តួចផ្តើមគំនិតនោះទេ ។ កូនក្តីខ្លួនបានដាក់បញ្ចាំប្លង់មួយទៀតបានប្រាក់ ៨.០០០ (ប្រាំបីពាន់)ដុល្លាអាមេរិក ហើយបានបង់ការប្រាក់ជាប្រចាំ ដូច្នេះកូនក្តីខ្លួនពុំមានចេតនាបន្លំអ្វីនោះទេ សូមឲ្យក្រុមប្រឹក្សាជំនុំជម្រះលើកលែងចោទប្រកាន់លើកូនក្តីខ្លួន ។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យរូបខ្លួនផង និងសុំឲ្យតុលាការលើកលែងចោទប្រកាន់ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឲ្យជនជាប់ចោទ ។

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។



Scanned by CamScanner

## យល់ឃើញថា

១-កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ឈ្មោះ [redacted] និងគូកន (ឈ្មោះ [redacted])បានក្លែងបន្លំឯកសារដោយបានក្លែងលិខិតផ្ទេរសិទ្ធកាន់កាប់ដី/ផ្ទះលេខ ១១៣ ប.ជ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ហើយឈ្មោះ [redacted] បានបន្លំធ្វើជាឈ្មោះ [redacted] រួចនាំគ្នាយកឯកសារក្លែងបន្លំទាំងនេះទៅដាក់តម្កល់ខ្ចីប្រាក់ពីឈ្មោះ [redacted] បានប្រាក់រួច ក្រោយមកក៏នាំគ្នាគេចខ្លួនបាត់តែម្តង ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយនៅមុខអង្គសវនាការថាៈ ឈ្មោះ [redacted] បានឲ្យខ្លួនបានដើរតួជាឈ្មោះ [redacted] ដើម្បីទៅខ្ចីប្រាក់ពីឈ្មោះ [redacted] ចំនួន ១០.០០០ (មួយម៉ឺន)ដុល្លាអាមេរិក និងបានយកលិខិតផ្ទេរសិទ្ធកាន់កាប់ដី/ផ្ទះលេខ ១១៣ ប.ជ ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៧ ដើម្បីជាការបញ្ចាំ ខ្លួនទទួលស្គាល់ថារូបក្នុងអត្តសញ្ញាណប័ណ្ណថតចម្លងដែលមានឈ្មោះ [redacted] គឺជារូបរបស់ខ្លួន ដោយខ្លួនបានឲ្យរូបថត និងអត្តសញ្ញាណប័ណ្ណរបស់ខ្លួនឲ្យឈ្មោះ [redacted] ជាចម្លើយគួរជឿតប្បីពិចារណា ។

៣-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយនៅមុខអង្គសវនាការថាៈ ឈ្មោះ [redacted] និងឈ្មោះ [redacted] បានទំនាក់ទំនងមកខ្លួនដើម្បីឲ្យប្រាក់ទៅឈ្មោះ [redacted] ខ្ចីចំនួន ១០.០០០ (មួយម៉ឺន)ដុល្លាអាមេរិក ដើម្បីទៅលោះប្លង់នៅធនាគារ ដោយឈ្មោះ [redacted] បានប្រាប់ខ្លួនថាគាត់ឈ្មោះ [redacted] និងបានប្រគល់អត្តសញ្ញាណប័ណ្ណថតចម្លងរបស់ឈ្មោះ [redacted] មកខ្លួន ប៉ុន្តែរូបនៅក្នុងអត្តសញ្ញាណប័ណ្ណនោះគឺជារូបរបស់ឈ្មោះ [redacted] ទៅវិញ ។ នៅពេលលោះប្លង់បានហើយឈ្មោះ [redacted] បានធ្វើកិច្ចសន្យាខ្ចីប្រាក់ជាមួយខ្លួននិងបានដាក់លិខិតផ្ទេរសិទ្ធកាន់កាប់ដី/ផ្ទះលេខ ១១៣ ប.ជ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដើម្បីជាការបញ្ចាំ ប៉ុន្តែនៅពេលខ្លួនបានយកប្លង់ទៅសួរមេឃុំ ទើបដឹងថាប្លង់ដែលឈ្មោះ [redacted] បានបញ្ចាំខ្លួននោះជាឯកសារក្លែងក្លាយ ដែលមានលិខិតបដិសេធក្រាក្លែងក្លាយ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៦ របស់មេឃុំពើក ជាចម្លើយគួរឲ្យជឿ។

៤-តាមលិខិតបដិសេធក្រាក្លែងក្លាយ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ របស់មេឃុំពើក បានបញ្ជាក់ថាៈ សូមបដិសេធលិខិតលេខៈ ១១៣ ប.ជ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ និងលិខិតលេខ ១៩១ ឃ.ព ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១១ ដោយហត្ថលេខា ត្រាឃុំ និងឈ្មោះខ្លួនផ្ទាល់ជាមេឃុំ សុទ្ធតែក្លែងក្លាយទាំងអស់ ។

៥-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ព្រមទាំងឯកសារជាភស្តុតាងនៅក្នុងសំណុំរឿង គឺជាភស្តុតាងដាក់បន្ទុកមានលក្ខណៈគ្រប់គ្រាន់ដែលគប្បីលើកមកពិចារណា ។

៦-ពិនិត្យលើសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានទៅខ្ចីប្រាក់ពីឈ្មោះ [redacted] ដោយបានយកលិខិតផ្ទេរសិទ្ធកាន់កាប់ដី/ផ្ទះលេខ ១១៣ ប.ជ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលជាឯកសារក្លែងក្លាយមកដាក់បញ្ចាំ គឺជាការសហការណ៍គ្នាប្រព្រឹត្តដោយចេតនានូវបទល្មើស "ក្លែងបន្លំឯកសារសារធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង" ដែលច្បាប់បញ្ញត្តិឲ្យនិយមន័យ និងផ្តន្ទាទោសតាមមាត្រា ៦២៩ និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ។

៧-ជនជាប់ចោទជានីតិជន មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវលើអំពើរបស់ខ្លួន ។



Scanned by CamScanner

៨-អំពើរបស់ជនជាប់ចោទ បានក្លែងបន្លំលិខិតយថាភូតដើម្បីធ្វើការកត់សម្គាល់សិទ្ធិ និងបានប្រើប្រាស់ឯកសារសាធារណៈក្លែងដើម្បីទទួលបាននូវប្រាក់កម្ចី ដែលច្បាប់បញ្ញត្តិថាជាបទល្មើសព្រហ្មទណ្ឌ និងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

៩-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ[redacted]ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ និងឈ្មោះ[redacted]ភេទស្រី អាយុ៤៧ឆ្នាំ ជាតិខ្មែរ ពីបទ ក្លែងបន្លំឯកសារសារធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៦២៩ និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ។

១០-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ បានសន្និដ្ឋានអំពីអង្គហេតុ និងធាតុផ្សំនៃបទល្មើសព្រហ្ម ទាំងភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ហើយបានសំណូមពរសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទមាន លក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីលើកយកមកពិចារណា ។

១១-លោក[redacted]មេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ[redacted]បានស្នើសុំឲ្យតុលាការកែប្រែបទចោទប្រកាន់លើកូនក្តីខ្លួន ពីបទ ក្លែងបន្លំឯកសារសារធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង ទៅជាបទ ឆបោក វិញ ពុំមានភស្តុតាងត្រឹមត្រូវតាមច្បាប់ គប្បីបដិសេធចោល ។

១២-លោក[redacted]មេធាវីការពារក្តីឲ្យជនជាប់ចោទឈ្មោះ[redacted] បានស្នើសុំឲ្យតុលាការលើលែងចោទប្រកាន់លើកូនក្តីខ្លួន ពុំមានភស្តុតាងត្រឹមត្រូវតាមច្បាប់ គប្បីបដិសេធចោល ។

១៣-ជនជាប់ចោទឈ្មោះ[redacted] បាននិយាយសម្តីចុងក្រោយថាៈ សុំឲ្យតុលាការលើកលែងចោទប្រកាន់ ពុំមានភស្តុតាងត្រឹមត្រូវតាមច្បាប់ គប្បីបដិសេធចោល ។

១៤-ជនជាប់ចោទឈ្មោះ[redacted]ក្រោយពីបានប្រព្រឹត្តបទល្មើសបានគេចខ្លួនមិនដឹងស្ថិតនៅទីកន្លែងណា គប្បីសម្រេចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ដើម្បីយកមកអនុវត្តទោសតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

១៥-ដើមបណ្តឹងរដ្ឋប្បវេណីបានទាមទារប្រាក់ដើមចំនួន ១០.០០០ (មួយម៉ឺន)ដុល្លារអាមេរិក តែដើមបណ្តឹងបានអះអាងថាខ្លួនបានទទួលការសងប្រាក់ចំនួន ២០០០ (ពីរពាន់)ដុល្លារអាមេរិក រួចហើយតុលាការនឹងសម្រេចតាមការទូទាត់សងប្រាក់ជាក់ស្តែង និងសំណងជម្ងឺចិត្តចំនួន ៥០០០ (ប្រាំពាន់)ដុល្លារអាមេរិក គប្បីតុលាការសម្រេចតាមស្ថានភាពជាក់ស្តែងនិងកំរិតជីវភាពរបស់ជនជាប់ចោទ ។

១៦-ពិនិត្យឲ្យដឹងដល់ជនជាប់ចោទឈ្មោះ[redacted]ទើបប្រព្រឹត្តបទល្មើសជាលើកដំបូង ដោយខ្វះការយល់ដឹង គប្បីតុលាការសម្រាលទោសដោយព្យួរទោសធម្មតា ។

**ទិនិច្ឆ័យសេចក្តី**

១-ផ្តន្ទាទោសលើៈ

ក.ឈ្មោះ[redacted]ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៥ (ប្រាំ) ឆ្នាំ តែទោសនេះអនុវត្តទោសគុកចំនួន ០៣ (បី) ឆ្នាំ ទោសនៅសល់ត្រូវព្យួរទោសធម្មតាតាមមាត្រា ១០៦, ១០៧, ១០៨ និងមាត្រា ១០៩ នៃក្រមព្រហ្មទណ្ឌ ។

ខ.ឈ្មោះ[redacted]ភេទស្រី អាយុ៤៧ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៥ (ប្រាំ) ឆ្នាំ ។

ពីបទ ក្លែងបន្លំឯកសារសាធារណៈ និងប្រើប្រាស់ឯកសារសាធារណៈក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ តាមបញ្ញត្តិមាត្រា ៦២៩ និងមាត្រា ៦៣០ នៃក្រមព្រហ្មទណ្ឌ ។



Scanned by CamScanner

២-ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] ភេទស្រី អាយុ៤៧ឆ្នាំ ដើម្បីយកមកអនុវត្តទោស តាមអំណាចសាលក្រមនេះ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-បង្គាប់ឲ្យឈ្មោះ [redacted] និងឈ្មោះ [redacted] រួមគ្នាសងប្រាក់ចំនួន ៨.០០០ (ប្រាំបីពាន់) ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន ១.០០០ (មួយពាន់) ដុល្លារអាមេរិក ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]

សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវឲ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា និងត្រា [redacted] |

---

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧
ក្រឡាបញ្ជី
[redacted]



Scanned by CamScanner